អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែង ប្រកួតសាងសង់ជាមួយគម្របដប**

**សិក្សាសង្គម (គំនូរ និងសកម្មភាពកសាង)**៖ ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបងបង្កើតរូបភាព

**ភាសាខ្មែរ (ការស្ដាប់)**៖ ស្ដាប់គេនិយាយ និងមានសមត្ថភាពស្ដាប់ដោយធ្វើតាមការណែនាំងាយៗ។

**គោលបំណង**

**សិក្សាសង្គម** ៖ រហ័សរហួនឈ្លាសវៃ និងប៉ិនប្រសប់ក្នុងការចាប់កាន់ បត់ សូន គូរ ហែក និងផាត់ពណ៌ឱ្យមានសោភ័ណ។

**ភាសាខ្មែរ** ៖ ប្រាប់បានពីសូរសម្លេងផ្សេងៗនៅក្នុងបរិស្ថាន។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ គម្របដបមួយចំនួន

**កម្រិតសិក្សា** ៖ មធ្យម និង ខ្ពស់

**ការរៀបចំ** ៖ ត្រៀមគម្របដប២ឈុតសម្រាប់ក្រុមនីមួយៗ ដែលមួយឈុតមាន ១៥ ឬ ២០ គម្របដប

**សេចក្ដីណែនាំ**៖

1. និយាយទាក់ទងទៅនឹងជនពិការភ្នែក។ ពិភាក្សាគ្នាពីការធ្វើអ្វីមួយដោយមើលមិនឃើញ។
2. បង្ហាញក៏ដូចជាពន្យល់ក្មេងថា ថ្ងៃនេះពួកគេទាំងអស់នឹងត្រូវធ្វើការជាគូរៗពីរនាក់ ដោយធ្វើជាពិការភ្នែក និងប្រាប់ដៃគូរឱ្យធ្វើអ្វីមួយដោយគ្រាន់តែនិយាយប្រាប់តាមសម្លេង។
3. បែងចែកក្មេងៗទៅជាគូរៗឱ្យហើយ ដើម្បីមានការងាយស្រួលក្នុងការលេងល្បែងនេះ។
4. ពន្យល់ក្មេងៗពីល្បែងសកម្មភាពនេះឱ្យបានច្បាស់។
    - ចែកក្មេងៗជាក្រុមនីមួយៗ (១ក្រុមមានពីរនាក់) ។
    - ក្មេងទី១ អង្គុយចុះដែលមានគម្របដបមួយឈុតនៅចំពីមុខ ។
    - ក្មេងទី២ អង្គុយចុះដូចគ្នា តែត្រូវបែរខ្នងដាក់គ្នា ហើយមានគម្របដប នៅពីមុខដូចគ្នា។

- ❖ ក្មេងទី១ (ត្រូវធ្វើការសម្រេចចិត្តថាឱ្យក្មេង ទី១ ឬ ទី២ ជាអ្នកចាប់ផ្ដើមនិយាយមុន) ចាប់ផ្តើមរៀបគម្រូបដបរបស់ខ្លួនជារាងអ្វីក៏បានដែលខ្លួនស្រឡាញ់ចូលចិត្ត បន្ទាប់មកនិយាយប្រាប់ទៅក្មេងទី២ ឱ្យរៀបគម្របដបរបស់គេឱ្យដូចទៅនឹងក្មេងទី១ដែរដោយមិនអនុញ្ញាតឱ្យមើលគ្នានោះទេ (ល្បែងនេះលេងម្តងបានតែមួយក្រុមទេ មានន័យថាម្តង២នាក់) ។
- ❖ ក្នុងមួយរូបភាព ក្មេងដែលត្រូវធ្វើតាមដៃគូនោះ គឺមានឱកាសធ្វើតាមតែ១ដងតែប៉ុណ្ណោះ បើលើសពីមួយដងនឹងចាត់ទុកថាជាមោឃៈ។
- ❖ ក្មេងៗដែលនៅកន្លែងទាំងអស់ប្រាប់ពួកគេឱ្យនៅស្ងៀម មិនគួរមាត់ មិនគួរប្រាប់ទេ ។
- ❖ នៅពេលដែលសាងសង់រួចហើយ ក្មេងទាំង២ត្រូវផ្លាស់ប្តូរកន្លែងគ្នា នឹងអាចមើលរូបភាពថាដូចគ្នាដែរឬទេ?
- ❖ ក្រុមណាដែលសាងសង់រូបភាពដូចគ្នាបាន គឺជាក្រុមដែលអស្ចារ្យ ហើយទះដៃអបអរសាទរឱ្យពួកគេផង។

5. មុននឹងលេងសូមអ្នកហៅក្មេងណាម្នាក់ មកលេងសាកល្បងឱ្យពួកគេទាំងអស់គ្នាបានមើលឱ្យច្បាស់ជាមុនសិន។
6. ក្មេងដែលនៅក្នុងក្រុមអាចសួរគ្នា ដើម្បីឱ្យច្បាស់ពីការធ្វើរូបភាពរបស់ពួកគេបានដោយសេរី។